ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

**លេខ និង ឈ្មោះសំណុំរឿង ៖ ០៤៧/២០ - ឡុងមេត អេហ្វ៊ីខលឈ័រ**
**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២០**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **អ៊ឹង សុទ្ធី**
អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **អន ណន**
ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

**១- ភាគីនិយោជក**

ឈ្មោះ ៖ **ក្រុមហ៊ុន ឡុងមេត អេហ្វ៊ីខលឈ័រ ៦.ក**
អាសយដ្ឋាន ៖ ភូមិត្រពាំងភ្លាំង ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត
ទូរស័ព្ទ ៖ ០១៦ ៨៤ ៥១ ៨១ ទូរសារ ៖ គ្មាន
តំណាងភាគីនិយោជកចូលរួមសវនាការ៖

| | |
|---|---|
| ១- លោក សួង ហួត | ទីប្រឹក្សាក្រុមហ៊ុន |
| ២- លោក ប៊ុន សាវ | ប្រធានផ្នែកធនធានមនុស្ស និងរដ្ឋបាល |

**២- ភាគីកម្មករនិយោជិត**

ឈ្មោះ ៖ **អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន ឡុងមេត អេហ្វ៊ីខលឈ័រ ៦.ក**
អាសយដ្ឋាន ៖ ភូមិត្រពាំងភ្លាំង ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត
ទូរស័ព្ទ ៖ ០១៦ ៥៧ ០១ ២៦ / ០៨៨ ៩៦ ៨៤ ០២២ ទូរសារ ៖ គ្មាន
តំណាងភាគីកម្មករនិយោជិតចូលរួមសវនាការ៖

| | |
|---|---|
| ១- លោក ជួង វាសនា | មន្ត្រីច្បាប់CLC |
| ២- លោក កាន សុគារ | មន្ត្រីCLC |
| ៣- លោក ធន សុងឃុយ | តំណាងCLC |
| ៤- លោក ហេង ជឿន | ប្រធានសហព័ន្ធសហជីពកម្មករវិស័យកសិកម្ម |
| ៥- លោក ឈឹម គ្រុត | ប្រធានសហជីព (មូលដ្ឋាន) |

៦- លោកស្រី ស៊ុំ ណេន លេខាធិការនី

៧- លោក ខឹម ឡុក សកម្មជន

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

- ស្នើក្រុមហ៊ុនបញ្ឈប់ការដាក់កំណត់ការងារច្រើនហួសហេតុពេក អោយកម្មករវៃចេក ដោយមិនអោយលើសពី ២០០០ដើម ក្នុងមួយនាក់ និងផ្ដល់ប្រាក់រង្វាន់ចំនួន ៥០$ ដល់កម្មករនិយោជិតដែលធ្វើការគ្រប់ចំនួនដូចក្រុមហ៊ុនបានផ្ដល់ជូនកន្លងមក។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលទទួលអំណាចក្នុងការចេញសេចក្ដីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្ដីពីការងារឆ្នាំ១៩៩៧ ប្រកាសស្ដីពីក្រុមប្រឹក្សាអាជ្ញាកណ្ដាល លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្ដាល ដែលភ្ជាប់ជាឧបសម្ព័ន្ធ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្ដីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្ដាលលេខ ១៨៥/២០ ក.ប/ប្រ.ក.វ.ក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ (អាណត្តិទី១៨)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្ដីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្ដីពីការងារ។ ប៉ុន្តែ ការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្ដីអំពីការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន ឡុងមេត អេហ្គ្រីខលឈ័រ ឯ.ក លេខ ២៥២/២០ មកបវ/កព ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សា-អាជ្ញាកណ្ដាល នៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២០។

## សវនាការ និង សន្ទេបនីតិវិធី

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្ដាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ ៖** ថ្ងៃអង្គារ ១៤កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០ វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក។

**បញ្ហានីតិវិធី ៖**

នៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០ មន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ខេត្តកំពត បានទទួលពាក្យបណ្ដឹងរបស់កម្មករនិយោជិតនៃក្រុមហ៊ុន ឡុងមេត អេហ្គ្រីខលឈ័រ ស្ដីពីការទាមទារឱ្យក្រុមហ៊ុនដោះស្រាយលក្ខខណ្ឌការងារចំនួន ៤ចំណុច។ បន្ទាប់ពីទទួលពាក្យបណ្ដឹងនេះមក មន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ខេត្តកំពត បានចាត់មន្ត្រីជំនាញឱ្យដោះស្រាយវិវាទការងារនេះ ទៅតាមនីតិវិធីច្បាប់ នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០ ដោយទទួលបានលទ្ធផលសះជានឹងគ្នាចំនួន ៣ចំណុច។ ចំណុចមិនសះជាចំនួន ១ចំណុច ដែលនៅសល់ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្ដាល នៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២០ តាមរយៈរបាយការណ៍ស្ដីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ឡុងមេត អេហ្គ្រីខលឈ័រ លេខ ២៥២/២០ មកបវ/កព ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២០។ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល បានអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងផ្សះផ្សា នៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២០ វេលាម៉ោង ៨ និង ៣០ នាទី ព្រឹក។ ភាគីទាំងពីរមានវត្តមាននៅក្នុងសវនាការ តាមការអញ្ជើញរបស់លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកនូវអង្គហេតុផ្សេងៗ ដែលទាក់ទងទៅនឹងចំណុចវិវាទមិនសះជានេះ និងបានផ្សះផ្សាលើចំណុចវិវាទនេះបន្ថែមទៀត ប៉ុន្តែ មិនទទួលបានលទ្ធផលសះជានឹងគ្នាទេ។

នៅក្នុងសំណុំរឿងនេះ ភាគីជ្រើសរើសសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកំណត់ថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០២០ ជាថ្ងៃផុតកំណត់ផ្តល់ឯកសារភស្តុតាង និងថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២០ ជាថ្ងៃផុតកំណត់ជំទាស់ឯកសារភស្តុតាង។

ភាគីទាំងពីរបានឯកភាពពន្យារកាលបរិច្ឆេទនៃការចេញសេចក្តីបង្គាប់អាជ្ញាកណ្តាល ពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២០ ទៅយ៉ាងយូរ ត្រឹមថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២០ វិញ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

## ភស្តុតាង

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

## ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន

**ក- ឯកសារបានទទួលពីភាគីនិយោជក ៖**

១- លិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២០ របស់លោក ឈិន ជីងឡុង ជានាយកប្រតិបត្តិរងនៃក្រុមហ៊ុន ឡុងមេត អេហ្គ្រីខលឈឺរ ឯ.ក ផ្ទេរសិទ្ធិជូនលោក សួង ហួត ជាអ្នកប្រឹក្សាយោបល់ និងលោក ប៊ុន សាវ ជាប្រធានរដ្ឋបាល។

២- លិខិតចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០២០ របស់ក្រុមហ៊ុន ឡុងមេត អេហ្គ្រីខលឈឺរ ឯ.ក គោរពជូនលោកប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពត ស្តីពីសំណើរសុំលើកពេលនៃការផ្សះផ្សាវិវាទការងាររួមនៃក្រុមហ៊ុន ឡុងមេត អេហ្គ្រីខលឈឺរ ឯ.ក ពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ ទៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២០។

៣- លិខិតអញ្ជើញរបស់ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពត ជម្រាបមក លោកនាយកក្រុមហ៊ុន ឡុងមេត អេហ្គ្រីខលឈឺរ ឯ.ក ស្តីពីមកធ្វើការផ្សះផ្សាតាមពាក្យបណ្តឹងរបស់កម្មករនិយោជិត។

៤- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មក្រុមហ៊ុន ឡុងមេត អេហ្គ្រីខលឈឺរ ឯ.ក លេខ MOC-៦១៤០០៩១ ពណ.ចបព ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៧។

៥- ប័ណ្ណពន្ធប៉ាតង់ក្រុមហ៊ុន ឡុងមេត អេហ្គ្រីខលឈឺរ ឯ.ក លេខ PTL ២០២០០៣៤៣៨២ អពដ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២០។

THE ARBITRATION COUNCIL

៦- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន ឡុងមេត អេហ្វ្រឺខលឈឺរ ឯ.ក ចុះទិដ្ឋាការ លេខ ២១០ ក.ប/អក/អធក ចុះថ្ងៃសុក្រ ១១កើត ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៨ ដោយប្រធាននាយកដ្ឋានអធិការកិច្ចការងារ។

៧- លក្ខន្តិកៈក្រុមហ៊ុន ឡុងមេត អេហ្វ្រឺខលឈឺរ ឯ.ក បានតម្កល់ទុកលេខ ១៥៧៥/១៨ គ.វ.ក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៨ នៅនាយកដ្ឋាននិតិវិធី និងច្បាប់វិនិយោគ គ.វ.ក។

៨- សារណារបស់ក្រុមហ៊ុន ឡុងមេត អេហ្វ្រឺខលឈឺរ ឯ.ក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០។

៩- បញ្ជីរាយនាមកម្មករដែលស្នើសុំមើលថៃរលើសពី ២៥០០ដើម។

១០- កិច្ចសន្យាការងារមានថិរវេលាកំណត់សម្រាប់កម្មករមើលថែទាំចេក និងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ របស់ឈ្មោះ អុង កំព្រា។

១១- កិច្ចសន្យាការងារមានថិរវេលាកំណត់សម្រាប់កម្មករមើលថែទាំចេក សំបុត្របញ្ជាក់កំណើត និងបញ្ជីរាយនាមមនុស្សស្នាក់នៅក្នុងបន្ទុករបស់ឈ្មោះ ពៅ ជា។

១២- កិច្ចសន្យាការងារមានថិរវេលាកំណត់សម្រាប់កម្មករមើលថែទាំចេករបស់ឈ្មោះ កែត ធ្លួញ។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖**

១- លិខិតចុះថ្ងៃអង្គារ ១៥កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី០១ ខែកញ្ញា ឆ្នាំ ២០២០ របស់តំណាងកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមក្នុងក្រុមហ៊ុន ឡុងមេត អេហ្វ្រឺខលឈឺរ ឯ.ក គោរពជូន លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីស្នើសុំជូនសារណានៃក្រុមហ៊ុន ឡុងមេត អេហ្វ្រឺខលឈឺរ ឯ.ក។

២- វិញ្ញាបនបត្រចុះបញ្ជីអង្គការវិជ្ជាជីវៈរបស់សហជីពកម្មករនិយោជិតនៃក្រុមហ៊ុន ឡុងមេត អេហ្វ្រឺខលឈឺរ ឯ.ក លេខ ២៩៧/១៩ កប/កព ចុះថ្ងៃព្រហស្បតិ៍ ១កើត ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៩។

៣- លិខិតលេខ ២៩៦/១៩ កប/កព ចុះថ្ងៃព្រហស្បតិ៍ ១កើត ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៩ របស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បញ្ជាក់ថា សហជីពកម្មករនិយោជិតនៃក្រុមហ៊ុន ឡុងមេត អេហ្វ្រឺខលឈឺរ ឯ.ក ជាអង្គការវិជ្ជាជីវៈមួយត្រូវបានចុះបញ្ជីនៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពត និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ ចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ។

៤- ពាក្យបណ្តឹងរបស់កម្មករនិយោជិត និងសហជីពកម្មករនិយោជិតនៃក្រុមហ៊ុន ឡុងមេត អេហ្វ្រឺខលឈឺរ ឯ.ក គោរពជូន ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពត ស្តីពីស្នើសុំលោកប្រធានជួយដោះស្រាយវិវាទការងាររួម រវាងកម្មករនិយោជិត និងនិយោជកនៃក្រុមហ៊ុន ឡុងមេត អេហ្វ្រឺខលឈឺរ ឯ.ក ចុះថ្ងៃអង្គារ ៩រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០។

៥- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ឡុងមេត អេហ្វ្រឺខលឈឺរ ឯ.ក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០។

ARBITRATION COUNCIL

៦- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ឡុងមេត អេហ្គ្រីខលឈ័រ ឯ.ក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០។

៧- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ឡុងមេត អេហ្គ្រីខលឈ័រ ឯ.ក ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០។

៨- កំណត់ហេតុធ្វើនៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២០ របស់កម្មករនៃក្រុមហ៊ុន ឡុងមេត អេហ្គ្រីខលឈ័រ ឯ.ក។

៩- លិខិតអះអាងចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២០ របស់កម្មករនៃក្រុមហ៊ុន ឡុងមេត អេហ្គ្រីខលឈ័រ ឯ.ក។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ឡុងមេត អេហ្គ្រីខលឈ័រ ឯ.ក លេខ ២៥២/២០ មកប/កព ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ឡុងមេត អេហ្គ្រីខលឈ័រ ឯ.ក ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០។

៣- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ឡុងមេត អេហ្គ្រីខលឈ័រ ឯ.ក លេខ ២៥៤ ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពត។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ៣០៦ កប/អក/វក/លកអ. ចុះថ្ងៃពុធ ៨កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២០។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ៣០៧ កប/អក/វក/លកអ. ចុះថ្ងៃពុធ ៨កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២០។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖**

- ក្រុមហ៊ុន ឡុងមេត អេហ្គ្រីខលឈ័រ ឯ.ក គឺជាក្រុមហ៊ុនមានសកម្មភាពចម្បងផ្នែកកសិកម្ម។ យោងតាមការលើកឡើងរបស់និយោជកនៅថ្ងៃសវនាការ បច្ចុប្បន្នក្រុមហ៊ុននេះ មានជួលកម្មករនិយោជិតសរុបចំនួន ៤៧០នាក់។

**ចំណុចវិវាទ៖ ភាគីកម្មករនិយោជិតទាមទារ ឱ្យនិយោជកបញ្ឈប់ការកំណត់ការងារច្រើនហួសហេតុពេក ឱ្យកម្មករនិយោជិតថែទាំដើមចេក ដោយមិនឱ្យលើសចំនួន ២០០០ដើម ក្នុងម្នាក់ និងផ្តល់ប្រាក់រង្វាន់ចំនួន ៥០ដុល្លារអាមេរិក ដល់កម្មករនិយោជិតដែលធ្វើការគ្រប់ចំនួនកំណត់ ដូចនិយោជកបានផ្តល់ជូនកន្លងមក**

- ភាគីកម្មករនិយោជិតបញ្ជាក់ការទាមទារ ឱ្យនិយោជកអនុវត្តគោលការណ៍ចាស់ ដោយឱ្យកម្មករនិយោជិតម្នាក់ថៃទាំដើមចេកចំនួន ២០០០ដើម និងផ្តល់ប្រាក់រង្វាន់ចំនួន ៥០ដុល្លារអាមេរិក រៀងរាល់ខែ។
- ភាគីទាំងពីរទទួលស្គាល់ថា ៖
  - ចាប់តាំងពីឆ្នាំ២០១៨មក និយោជកបានកំណត់ឱ្យកម្មករនិយោជិតម្នាក់មើលថែដើមចេកចំនួន ២០០០ដើម និងផ្តល់ប្រាក់រង្វាន់ចំនួន ៥០ដុល្លារអាមេរិក ក្នុងមួយខែ ដល់កម្មករនិយោជិតណាដែលអាចមើលថែដើមចេកគ្រប់ចំនួនកំណត់នេះ។
  - ចាប់ពីខែកក្កដា ឆ្នាំ២០២០មក និយោជកបានចាប់ផ្តើមផ្លាស់ប្តូរមកអនុវត្តគោលការណ៍ថ្មីដោយកំណត់ឱ្យកម្មករនិយោជិតថៃទាំដើមចេកចំនួន ២៥០០ដើម ក្នុងរយៈពេលជាអតិបរមា ៩ខែ និងកម្មករនិយោជិតអាចទទួលបានប្រាក់រង្វាន់នៅពេលប្រមូលកសិផល។ និយោជកអនុវត្តគោលការណ៍ថ្មីជាមួយកម្មករនិយោជិតដែលព្រមព្រៀងទទួលយកលក្ខខណ្ឌថ្មីទាំងនេះ យ៉ាងណាមិញសម្រាប់កម្មករនិយោជិតដែលមិនឯកភាពលើគោលការណ៍ថ្មីនេះ និយោជកនៅតែបន្តអនុវត្តគោលការណ៍ចាស់ជាមួយពួកគាត់ដដែល ដោយឱ្យមើលថែដើមចេក ២០០០ដើម និងផ្តល់ប្រាក់រង្វាន់ ៥០ដុល្លារអាមេរិក ក្នុងមួយខែ ដដែល។
  - ករណីដែលមានកម្មករនិយោជិត ដែលព្រមអនុវត្តគោលការណ៍ថ្មីបន្ថែមទៀត នោះនិយោជកនឹងឱ្យកម្មករនិយោជិតនោះ ទៅធ្វើការនៅតំបន់ដែលមានកម្មករនិយោជិតកំពុងអនុវត្តគោលការណ៍ចាស់ ហើយកម្មករនិយោជិតដែលនៅតែអនុវត្តគោលការណ៍ចាស់នោះនឹងផ្លាស់ប្តូរទៅធ្វើការនៅតំបន់ផ្សេងវិញ។
- ភាគីកម្មករនិយោជិតបានបញ្ជាក់មូលហេតុនៃការទាមទារថា ៖
  - កន្លងមក កម្មករនិយោជិតត្រូវធ្វើការឥតឈប់ឈរ ហើយត្រូវធ្វើការទាំងថ្ងៃឈប់បុណ្យ និងថ្ងៃសម្រាក ហើយកម្មករនិយោជិតខ្លះត្រូវនាំកូននិងបងប្អូនមកជួយ ដើម្បីមើលថែដើមចេកចំនួន ២០០០ដើម ឱ្យបានសម្រេច។ ហេតុនេះ កម្មករនិយោជិតមិនមានលទ្ធភាពដើម្បីមើលថែដើមចេកលើសពី ២០០០ដើម នោះទេ។
  - និយោជកអនុវត្តគោលការណ៍ថ្មី ដោយមិនទាន់ទទួលបានទិដ្ឋាការពីអធិការកការងារ និងដោយមិនបានពិគ្រោះយោបល់ជាមួយសហជីព។
  - នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០ និយោជកបានព្រមព្រៀងគ្នាជាមួយកម្មករនិយោជិតថានិយោជកនឹងកំណត់ឱ្យកម្មករនិយោជិតម្នាក់មើលថែដើមចេកចំនួន ២០០០ដើម ដោយផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត។
  - និយោជកនឹងទទួលយកកម្មករនិយោជិតថ្មីដែលយល់ព្រមអនុវត្តគោលការណ៍ថ្មី និងផ្លាស់ប្តូរតំបន់ការងាររបស់កម្មករនិយោជិតដែលមិនយល់ព្រមអនុវត្តគោលការណ៍ថ្មី រហូតដល់ថ្ងៃមួយនិយោជកនឹងរំលាយកិច្ចសន្យាការងាររបស់កម្មករនិយោជិតដែលមិនព្រមអនុវត្តគោលការណ៍ថ្មី ហើយសហជីពនឹងត្រូវរលាយ ពីព្រោះពួកគាត់សុទ្ធតែជាសមាជិកសហជីព។ នេះសបញ្ជាក់ឱ្យឃើញថានិយោជកបានបង្ខិតបង្ខំ និងមានការរើសអើងសហជីព។
- ភាគីនិយោជកមិនអាចផ្តល់ជូនតាមការទាមទាររបស់ភាគីកម្មករនិយោជិតបានទេ ដោយមូលហេតុថា ៖

- ○ យោងតាមមាត្រា២ នៃច្បាប់ស្តីពីការងារ និយោជកមានសិទ្ធិចាត់ចែង និងគ្រប់គ្រងសហគ្រាសរបស់ខ្លួន ដើម្បីជានានិរន្តភាពនៃសហគ្រាសនោះ ដូចនេះ និយោជកមានសិទ្ធិចាត់ចែងអនុវត្តគោលការណ៍ នៃការកំណត់ការងារ និងប្រាក់រង្វាន់ថ្មីបាន។
  - ○ គោលការណ៍ថ្មីនេះ គឺនិយោជកបានធ្វើការសិក្សាពីកសិដ្ឋាននៅខេត្តរតនគិរី, ខេត្តមណ្ឌលគិរី, ខេត្តកំពង់ចាម និងក្រៅប្រទេស ដែលដាំដំណាំចេកប្រភេទដូចគ្នា ហើយកសិដ្ឋានទាំងនេះអនុវត្តទទួលបានលទ្ធផលយ៉ាងជោគជ័យ។
  - ○ មុនអនុវត្តគោលការណ៍ថ្មីនេះ និយោជកក៏បានសិក្សាអំពីលទ្ធភាពរបស់កម្មករនិយោជិតក្នុងកសិដ្ឋានខ្លួនផ្ទាល់ដែរ តាមរយៈការងាររបស់កម្មករនិយោជិត ចាប់ពីឆ្នាំ២០១៨ រហូតមកដល់ពេលបច្ចុប្បន្ន និយោជករកឃើញថា មានកម្មករនិយោជិតលើសពីពាក់កណ្តាលនៃកម្មករនិយោជិតសរុប បានមើលថែដើមចេកលើសពី ២០០០ដើម ក្នុងម្នាក់។ កម្មករនិយោជិតដែលមិនអាចមើលថែដើមចេកចំនួន ២០០០ដើម បានសម្រេច គឺមកពីពួកគាត់ធ្វើការងារមិនគ្រប់ម៉ោងការងារដែលកំណត់ដោយក្រុមហ៊ុន និងអវត្តមានពីការងារ។
- លើសពីនេះ ភាគីនិយោជកបានបញ្ជាក់ថា ៖
  - ○ នៅក្នុងឆ្នាំ២០២០ ប្រទេសកម្ពុជាជួបប្រទះបញ្ហារាំងស្ងួតអូសបន្លាយរយៈពេលវែង ដែលធ្វើឱ្យដំណាំចេកជាងពាក់កណ្តាលនៅក្នុងកសិដ្ឋាននេះខូចខាត និងត្រូវបានកាប់ចោល។ លើសពីនេះ ការរីករាលដាលនៃជម្ងឺកូវីដ-១៩ ធ្វើឱ្យតម្លៃចេកនៅលើទីផ្សារអន្តរជាតិធ្លាក់ចុះ ដែលធ្វើឱ្យក្រុមហ៊ុនមានការខាតបង់ច្រើន។ យោងតាមស្ថានភាពទាំងនេះ និយោជកសម្រេចកែសម្រួលផែនការលក្ខណៈទ្រង់ទ្រាយធំ ដោយកំណត់អនុវត្តគោលការណ៍ថ្មីនៃការងារ និងប្រាក់រង្វាន់។
  - ○ គោលការណ៍ថ្មីផ្តល់ផលប្រយោជន៍ច្រើនជាងមុនដល់កម្មករនិយោជិត និងផ្តល់ផលចំណេញច្រើនជាងមុនដល់និយោជក ដោយនៅក្នុងគោលការណ៍ថ្មីនិយោជកកំណត់លក្ខខណ្ឌការងារ និងប្រាក់រង្វាន់ ដូចខាងក្រោម ៖
    - ➢ កំណត់ឱ្យកម្មករនិយោជិតម្នាក់មើលថែទាំដើមចេកចំនួន ២៥០០ដើម ក្នុងរយៈពេលជាអតិបរមា ៩ខែ ដោយទទួលបានប្រាក់ឈ្នួលគោលចំនួន ១៨០ ដុល្លារអាមេរិក ក្នុងមួយខែ សម្រាប់ខែទី១ ដល់ខែទី៦ និងទទួលបានប្រាក់ឈ្នួលគោលបន្ថែម ៧០ ដុល្លារអាមេរិកទៀត សរុបចំនួន ២៥០ ដុល្លារអាមេរិក ក្នុងមួយខែ សម្រាប់ខែទី៧ ដល់ខែទី៩ ចំពោះការងារកម្មករនិយោជិតត្រូវស្រោបស្ទងចេក ដើម្បីឱ្យផ្លែចេកបានគុណភាពល្អ។
    - ➢ នៅពេលប្រមូលផលនៃដើមចេកចំនួន ២៥០០ដើម និយោជកនឹងយកផ្លែចេកដែលប្រមូលផលសរុបមកថ្លឹងគីឡូ ហើយគុណនឹងអាត្រា ០.០៥ ដុល្លារអាមេរិក ក្នុងមួយគីឡូក្រាម។ ជាទូទៅ ដើមចេកមួយដើមអាចទទួលផលយ៉ាងតិច ២០គីឡូ ដូចនេះតាមអាត្រានេះ ដើមចេកចំនួន ២៥០០ដើម អាចទទួលបានប្រាក់សរុបចំនួន ២៥០០ ដុល្លារអាមេរិក។ ផលចំណេញចំនួន ២៥០០ ដុល្លារអាមេរិកនេះ នឹងត្រូវយកមកដកនឹងប្រាក់ឈ្នួលគោលសរុបក្នុងរយៈពេល ៩ខែ ដែលកម្មករនិយោជិតបានបើករួច ហើយភាគនៃផលចំណេញដែលនៅសល់ នឹងត្រូវផ្តល់ជូនកម្មករនិយោជិតបន្ថែមទៀត។ ការអនុវត្តនេះ គឺស្រដៀងគ្នានឹងការធ្វើការងារតាមបរិមាណផលិតផលដែរ

THE ARBITRATION COUNCIL

មានន័យថា បើពួកគាត់ធ្វើបានល្អ និងទទួលបានផលចេកច្រើន នោះគាត់នឹងបានប្រាក់ឈ្នួលបន្ថែមទៀតពេលប្រមូលផលចេក។

➢ ចំពោះប្រាក់រង្វាន់ ៥០ ដុល្លារអាមេរិក ក្នុងមួយខែ គឺនិយោជកបានប្តូរទៅជាប្រាក់រង្វាន់ប្រកួតប្រជែងកម្មករធ្វើមវិញ ដោយកម្មករនិយោជិតមានឱកាសទទួលបានប្រាក់រង្វាន់បន្ថែមទៀត តាមរយៈការប្រកួតប្រជែងបរិមាណកសិផលក្នុងថ្នាក់តំបន់ ចំពោះកម្មករនិយោជិតលេខ១ ទទួលបានប្រាក់រង្វាន់ ១០០ ដុល្លារអាមេរិក, លេខ២ បានរង្វាន់ ៥០ ដុល្លារអាមេរិក និងលេខ៣ បានរង្វាន់ ៣០ ដុល្លារអាមេរិក។ ចំណែកការប្រកួតប្រជែងថ្នាក់កសិដ្ឋានទាំងមូលកម្មករនិយោជិតលេខ១ ទទួលបានប្រាក់រង្វាន់ ៣០០ ដុល្លារអាមេរិក, លេខ២ បានប្រាក់រង្វាន់ ២០០ ដុល្លារអាមេរិក និងលេខ៣ បានប្រាក់រង្វាន់ ១០០ ដុល្លារអាមេរិក។

➢ ការអនុវត្តគោលការណ៍ការងារ និងប្រាក់រង្វាន់ថ្មីនេះ គឺកម្មករនិយោជិតទទួលបានប្រាក់រង្វាន់ ច្រើនជាងចំនួនប្រាក់រង្វាន់ ៥០ ដុល្លារអាមេរិក ក្នុងមួយខែ ដែលពួកគាត់ធ្លាប់ទទួលបានតាមគោលការណ៍ចាស់។

○ ហេតុមកដល់ពេលបច្ចុប្បន្ន កម្មករនិយោជិតចំនួនប្រមាណ ៧០ ភាគរយ នៃកម្មករនិយោជិតសរុប បានព្រមព្រៀងអនុវត្តគោលការណ៍ការងារ និងប្រាក់រង្វាន់ថ្មីនេះ ជាមួយនិយោជក។ កម្មករនិយោជិតចំនួន ១៥ ភាគរយ បានស្នើសុំដោយស្ម័គ្រចិត្តដើម្បីមើលថែដើមចេកលើសពី ២៥០០ដើម។ មានកម្មករនិយោជិតប្រហែលជា ៣០នាក់ជាងប៉ុណ្ណោះ ដែលមិនព្រមអនុវត្តគោលការណ៍ថ្មី។

**ហេតុផលនៃសេចក្តីសម្រេច ៖**

**ចំណុចវិវាទ ៖ ភាគីកម្មករនិយោជិតទាមទារ ឱ្យនិយោជកអនុវត្តគោលការណ៍ចាស់ ដោយឱ្យកម្មករនិយោជិតម្នាក់ថែទាំដើមចេកចំនួន ២០០០ដើម និងផ្តល់ប្រាក់រង្វាន់ចំនួន ៥០ ដុល្លារអាមេរិក រៀងរាល់ខែ**

ករណីនេះ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកអនុវត្តគោលការណ៍ចាស់ ដោយឱ្យកម្មករនិយោជិតម្នាក់ថែទាំដើមចេកចំនួន ២០០០ដើម និងផ្តល់ប្រាក់រង្វាន់ចំនួន ៥០ ដុល្លារអាមេរិក រៀងរាល់ខែ។ បច្ចុប្បន្ននិយោជកបានកំណត់គោលការណ៍ថ្មីនៃការងារ និងប្រាក់រង្វាន់ ហើយនិយោជកបានអនុវត្តគោលការណ៍ថ្មីនេះជាមួយតែកម្មករនិយោជិតណាដែលព្រមព្រៀងតែប៉ុណ្ណោះ។ យ៉ាងណាមិញ ភាគីកម្មករនិយោជិតនៅតែមានការព្រួយបារម្ភថា និយោជកនឹងបញ្ឈប់កម្មករនិយោជិតដែលមិនព្រមអនុវត្តគោលការណ៍ថ្មី នៅពេលដែលមានកម្មករនិយោជិតស្ម័គ្រចិត្តអនុវត្តគោលការណ៍ថ្មីមានចំនួនគ្រប់គ្រាន់។

ក្នុងករណីនេះ ផ្អែកលើអង្គហេតុខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកមិនឃើញថា មានអង្គហេតុជាក់លាក់ដែលពាក់ព័ន្ធនឹងការផ្លាស់ប្តូរតំបន់ការងាររបស់កម្មករនិយោជិតដែលមិនព្រមអនុវត្តគោលការណ៍ថ្មី និង/ឬការរំលាយកិច្ចសន្យាការងាររបស់កម្មករនិយោជិតដែលមិនព្រមអនុវត្តគោលការណ៍ថ្មីនៅឡើយទេ។ ជាងនេះទៀត កម្មករនិយោជិតដែលទាមទារនៅត្រង់ចំណុចវិវាទនេះ ក៏មិនទាន់មានអ្នកណាម្នាក់ត្រូវបាននិយោជកផ្លាស់ប្តូរតំបន់ការងារដោយគ្មានការព្រមព្រៀង ឬបញ្ឈប់ពីការងារដោយសារការមិនព្រមអនុវត្តគោលការណ៍ថ្មីនោះទេ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា វិវាទនេះមិនទាន់កើតឡើងទេ ដូច្នេះ វិវាទនេះ គឺជាវិវាទអំពីអនាគត។

កថាខណ្ឌទី១ នៃមាត្រា ៣១២ នៃច្បាប់ស្តីពីការងារចែងថា ៖ *"ក្រុមប្រឹក្សាអាជ្ញាកណ្តាល គ្មានការកិច្ចពិនិត្យបញ្ហាដទៃ ក្រៅពីបញ្ហាដែលមានបញ្ជាក់ក្នុងកំណត់ហេតុមិនព្រមសះជា ឬបញ្ហា ដែលកើតក្រោយការធ្វើកំណត់ហេតុ ជាផលវិបាកផ្ទាល់នៃការវិវាទនោះតែប៉ុណ្ណោះ"*។

នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយថា ៖ *"ក្រុមប្រឹក្សាអាជ្ញាកណ្តាល បង្កើតឡើងដើម្បីដោះស្រាយជម្លោះការងារ មិនមែនដើម្បីដោះស្រាយបញ្ហាដែលមិនទាន់កើតឡើងនោះទេ។ បន្ថែមពីនេះទៀត នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាល បដិសេធពិចារណាការទាមទារដែលមានកម្មវត្ថុជាវិវាទអនាគត" (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាល លេខ ៦៨/០៤-ស៊ីធីញ៉ាវ ហេតុផលនៃចំណុចវិវាទទី៤, លេខ ៣៦/០៦-ម៉ុងដូចតិច ហេតុផលនៃចំណុចវិវាទទី៥, លេខ ៥៨/០៧-០៨ ស្តារ ស្កតវែរ ហេតុផលនៃចំណុចវិវាទទី១ និងលេខ ១៥៥/១៣-កាតាត ហេតុផលនៃចំណុចវិវាទទី៤)*។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញា-កណ្តាលនៅក្នុងសំណុំរឿងមុនៗខាងលើដែរ ពោលគឺក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចដោះស្រាយវិវាទដែលមិនទាន់កើតឡើងនោះទេ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធពិចារណាការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកអនុវត្តគោលការណ៍ចាស់ ដោយឱ្យកម្មករនិយោជិតម្នាក់ថែទាំដើមចេកចំនួន ២០០០ដើម និងផ្តល់ប្រាក់រង្វាន់ចំនួន ៥០ ដុល្លារអាមេរិក រៀងរាល់ខែ។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សា-អាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ ៖

## សម្រេច និង បង្គាប់

**ចំណុចវិវាទ ៖**

- បដិសេធពិចារណាការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកអនុវត្តគោលការណ៍ចាស់ ដោយឱ្យកម្មករនិយោជិតម្នាក់ថែទាំដើមចេកចំនួន ២០០០ដើម និងផ្តល់ប្រាក់រង្វាន់ចំនួន ៥០ ដុល្លារអាមេរិក រៀងរាល់ខែ។

**ប្រភេទនៃសេចក្តីបង្គាប់ ៖ សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

សេចក្តីបង្គាប់នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ ចំនួន ០៨ ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរ ទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាល-វិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងរយៈពេលនេះទេ។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **អ៊ុំ សុទ្ធី**

ហត្ថលេខា ៖ ------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **អន ណាន**

ហត្ថលេខា ៖------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **ម៉ែន ម៉ិនឈា**

ហត្ថលេខា ៖ ------------------------------

THE ARBITRATION COUNCIL